ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌
លេខ ២០៤ ស.រ-៩៥

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# សារាចរអន្តរក្រសួង

## ឧបនាយករដ្ឋមន្ត្រី ជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## និង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ផ្ញើចំពោះ**

**-លោក អភិបាលខេត្ត ក្រុង**

**-លោក ប្រធានតុលាការខេត្ត ក្រុង**

**-លោក ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង**

**សូមជ្រាប។**

**កម្មវត្ថុ:** ស្តីអំពីសមត្ថកិច្ចនិងទំនាក់ទំនងការងាររវាងអភិបាលខេត្ត-ក្រុង ជាមួយប្រធានតុលាការ និងព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ។

តាមគោលការណ៍ច្បាប់ ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវកំណត់បែងចែកជាខេត្ត-ក្រុង ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អភិបាលខេត្ត-ក្រុង មានអំណាចជាតំណាងរាជរដ្ឋាភិបាល ក្រោមការគ្រប់គ្រងនិងដឹកនាំផ្ទាល់ពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការគ្រប់គ្រងដែនដី គ្រប់គ្រងមនុស្ស ទ្រព្យសម្បត្តិសាធារណៈ ថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សង្គម ជំរុញការអភិវឌ្ឍន៍លើគ្រប់វិស័យ ដើម្បីលើកដំកើងជីវភាពរស់នៅរបស់ប្រជារាស្ត្រអភិបាលខេត្ត-ក្រុង ជាតំណាងនៃផលប្រយោជន៍ជាតិ ។

ចំណែកតុលាការនិងអយ្យការអមតុលាការខេត្ត-ក្រុង ជាអំណាចឯករាជ្យកំណត់ដោយរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា១០៩ អំណាចនេះប្រធានតុលាការ និងព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ប្រើតាមរយៈសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ។ គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ មាត្រា ១១១ នៃរដ្ឋធម្មនុញ្ញ ។ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងការធានាឯករាជ្យនៃតុលាការនេះ មាត្រា ១១៣ ។

ចាប់តាំងពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូលរបស់ជាតិបានចូលជាធរមានបញ្ញត្តិរហូតមកដល់បច្ចុប្បន្ននេះ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ បានកត់សម្គាល់ឃើញថា លោកអភិបាលខេត្ត-ក្រុង លោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង នៅពុំទាន់យល់ច្បាស់អំពីការអនុវត្តន៍នូវតួនាទីភារកិច្ចដែលជាសមត្ថកិច្ចរបស់ខ្លួនក្នុងការទំនាក់ទំនងការងារតានៅក្នុងខេត្ត-ក្រុង ឱ្យបានល្អប្រសើរនៅឡើយ ។

ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចតទៅៈ

១-អភិបាលខេត្ត-ក្រុង ត្រូវទទួលខុសត្រូវនិងធានការគ្រប់គ្រង និងដឹកនាំវិស័យការងាររដ្ឋបាល និងនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងការងារសំខាន់ៗនៅក្នុងខេត្ត-ក្រុង របស់ខ្លួនរួមមានៈ

-ប្រមូលព័ត៌មានទូទៅជូនរាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ

-ផ្សព្វផ្សាយ អនុវត្ត ជំរុញ និងតាមដានការអនុវត្តន៍ច្បាប់ បទបញ្ញត្តិ និងសេចក្តីសម្រេចផ្សេងៗ

-មានអំណាចបញ្ជាលើអាជ្ញាធរនគរបាល

-មានអំណាចគ្រប់គ្រងលើមន្ត្រីរាជការតាមខ្សែបណ្តោយ និងតាមខ្សែទទឹងដែលបំពេញការងារនៅតាមមន្ទីរនានាក្នុងខេត្ត-ក្រុង ស្របតាមមាត្រា ២២ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

-មានអំណាចសម្របសម្រួល ជំរុញ និងត្រួតពិនិត្យលើមន្ត្រីរាជការ លើបណ្តាមន្ទីរជំនាញនានា របស់រដ្ឋតាំងនៅក្នុងខេត្ត-ក្រុង លើកលែងតែការងារជំនាញឯកទេសរបស់តុលាការ និងអយ្យការអមតុលាការខេត្ត-ក្រុងអភិបាលខេត្ត-ក្រុង ពុំមានអំណាចត្រួតពិនិត្យទេ ស្របតាមមាត្រា ១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

២-ប្រធានតុលាការនិងព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ត្រូវជានាអំណាចឯករាជ្យក្នុងការសម្រេចសេចក្តីដោយឆន្ទានុសិទ្ធិស្របច្បាប់របស់ខ្លួនតាងនាមប្រជារាស្ត្រខ្មែរ ក្នុងនាមព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដោយឡែកវិស័យការងាររដ្ឋបាល និងនយោបាយត្រូវស្ថិតនៅក្រោមការដឹកនាំរបស់អភិបាលខេត្ត-ក្រុង ដូច្នេះរបាយការណ៍ប្រចាំខែ ស្តីពីសកម្មភាពការងាររបស់តុលាការ និងអយ្យការអមតុលាការខេត្ត-ក្រុង ដែលផ្ញើមកក្រសួងយុត្តិធម៌ ជាខ្សែបណ្តោយត្រូវចម្លងជូនអភិបាលខេត្ត-ក្រុង ដើម្បីជាបជាព័ត៌មាន ។

អំណើះតទៅ បើមានប្រជារាស្ត្រប្តឹងអំពីវិវាទអ្វីមួយអភិបាលខេត្ត-ក្រុង ត្រូវណែនាំអោយប្រជារាស្ត្រនោះទៅប្តឹងទៅតុលាការខេត្ត-ក្រុង ឬបញ្ជូនពាក្យប្តឹងរបស់សាមីអ្នកប្តឹងទៅតុលាការ ដោយមិនត្រូវទទួលដោះស្រាយរឿងក្តីដែលជាសមត្ថកិច្ចរបស់តុលាការ និងអយ្យការអមតុលាការខេត្ត-ក្រុង ឡើយ ។

បើគូក្តីមិនឯកភាពនឹងសេចក្តីសម្រេចរបស់តុលាការ នោះត្រូវប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ ក្នុងរយៈពេលពីរខែ ពីព្រោះមានតែតុលាការថ្នាក់លើទេដែលមានសិទ្ធិត្រួតពិនិត្យសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ។

ក្រោយទទួលបានសារាចរនេះ សូមលោកអភិបាលខេត្ត-ក្រុង លោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ប្រជុំផ្សព្វផ្សាយនិងកំណត់អោយបានច្បាស់លាស់អំពីខ្លឹមសារនៃសារាចរនេះ រួចធ្វើរបាយការណ៍មកក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌អោយបានជ្រាប អំពីលទ្ធផលនៃការប្រជុំផ្សព្វផ្សាយសារាចរនេះ ។

សូមលោកអភិបាលខេត្ត-ក្រុង លោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង អនុវត្តតាមសេចក្តីណែនាំនៃសារាចរនេះ អោយបានល្អប្រសើរ ដើម្បីការពារផលប្រយោជន៍ច្បាប់តទៅ

ធ្វើនៅភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៩៥

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** | **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ចែម ស្គួន** | **ស ខេង** | **យូ ហុកគ្រី**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ដើម្បីជ្រាប

-ឯកសារ-កាលប្បវត្តិ